# គោលជំនឿ

**១.ព្រះ** គឺជាអាទិករបង្កើតផ្ទៃមេឃផែនដី និងរបស់គ្រប់សព្វសារពើដែលមានជីវិតនៅផែនដី និងនៅលើ មេឃ។
ព្រះបានសម្តែងអង្គទ្រង់ក្នុងភាពជាត្រៃឯក ព្រះវបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ ដែលស្មើភាពក្នុងអង្គទ្រង់ ក្នុងភាពជាព្រះ
អំណាចសិរីល្អ ហើយដូចគ្នាក្នុងលក្ខណៈសម្បត្តិ និងភាពគ្រប់លក្ខណ៍។
ព្រះវបិតា គឺជាអង្គបុគ្គលទីមួយនៅក្នុងភាពជាត្រៃឯក។

**២.ព្រះយេស៊ូវ** គឺជាព្រះដែលបានយកនិស្ស័យជាមនុស្សប្រសូត្រជាមួយនឹងស្រ្តីក្រមុំព្រហ្មចារី រស់នៅផែនដីក្នុងជីវិតដែលគ្មានបាប
សុគតនៅលើឈើឆ្កាងដើម្បីលោះបាបមនុស្ស រស់ពីស្លាប់ឡើងវិញ
និងត្រូវបានលើកឡើងទៅស្ថានសួគ៌គង់នៅខាងស្តាំព្រះដ៏ជាព្រះវបិតាដើម្បីធ្វើជាសម្តេចសង្ឃនៃយើង
ទ្រង់បំពេញតួនាទីជាអ្នកតំណាង អ្នកទូលអង្វរជំនួស និងជាអ្នកការពារ។
ព្រះយេស៊ូវនឹងយាងត្រលប់មកវិញម្តងទៀតក្នុងរូបកាយដដែលដើម្បីជំនុំជំរះផែនដីហើយតាំងរាជ្យនៃព្រះដ៏នៅអស់កល្បជានិច្ច។

**៣.ព្រះវិញ្ញាណបរិសុទ្ធ** គឺជាបុគ្គលម្នាក់ដែលចាក់ចុចលោកីយអំពីអំពើបាប សេចក្តីសុចរិត និងការជំនុំជំរះ
ទ្រង់ជាភ្នាក់ងារអេធិធម្មជាតិក្នុងការធ្វើអោយមានឡើង ការជ្រមុជ និងប្រថាប់ត្រាសំរាប់គ្រប់ទាំងអ្នកជឿ
អោយចូលទៅក្នុងរូបកាយនៃព្រះគ្រីស្ទ។ ទ្រង់គឺជាគ្រូខាងវិញ្ញាណដែលណែនាំគ្រប់ទាំងអ្នកជឿអោយចូលទៅក្នុងសេចក្តីពិត ។

**៤.មនុស្ស** យើងជឿថាមនុស្សត្រូវបានបង្កើតឡើងតាមលក្ខណៈនៃព្រះ និងដោយស្នាព្រះហស្តទ្រង់មិនមែនជា
ការវិវត្តន៍របស់ធម្មជាតិនោះទេ។ មនុស្សត្រូវបានបង្កើតឡើងសម្រាប់ថ្វាយសិរីល្អដល់ព្រះ, ថ្វាយបង្គំនិងបម្រើទ្រង់
និងដើម្បីប្រកបជាមួយនឹងព្រះអង្គ ។ មនុស្សបានធ្លាក់ចុះដោយការមិនស្តាប់បង្គាប់ព្រះដែលនាំ អោយមាន
សេចក្តីស្លាប់ទាំងខាងព្រលឹងវិញ្ញាណ និងខាងសាច់ឈាមដែលជាលទ្ធផលនៃការដាច់ចេញពីព្រះ។ ធម្មជាតិនៃមនុស្សត្រូវបានបង្ខូច
ហើយត្រូវបាត់បង់ទាំងស្រុង ស្លាប់ក្នុងការរំលងនិងអំពើបាប ហើយគ្មានលទ្ធភាពក្នុងការជួយសង្គ្រោះ ឬស្តារទំនាក់ទំនង
ដ៏សុចរិតជាមួយនឹងព្រះដោយខ្លួនឯងបានឡើយ។

**៥.សាតាំង** ជាអ្នកបង្ករបាប ហើយជាអ្នកបោកបញ្ឆោតយ៉ាងអស្ចារ្យនៅផែនដី ។ សាតាំងគឺជាវិញ្ញាណពិតប្រាកដ
មិនមែនគ្រាន់តែជានិមិត្តសញ្ញានៃសេចក្តីអាក្រក់នោះទេ ។ វាគឺជាទេវតាដែលបានធ្លាក់ចុះដែលនៅក្រោមការអនុញ្ញាត
របស់ព្រះវាត្រូវបានអោយគ្រប់គ្រងផែនដី និងប្រព័ន្ធនៃពិភពលោកជាបណ្តោះអាសន្ន ។ សាតាំងត្រូវបានប្រកាសថាជាសត្រូវរបស់ព្រះ
និងមនុស្សហើយនឹងត្រូវទទួលទោសអស់កល្បជានិច្ចនៅក្នុងបឹងដែលឆេះជាភ្លើង។

**៦.ព្រះគម្ពីរប៊ីប** មានសញ្ញាចាស់ និងសញ្ញាថ្មីត្រូវបានបណ្តាលអោយតែងដោយព្រះវិញ្ញាណបរិសុទ្ធគ្មានកំហុសនិង
ជាព្រះបន្ទូលដ៏មានអំណាចរបស់ព្រះ។ ព្រះបន្ទូលជាព្រះចេស្តារបស់ព្រះសំរាប់បង្រៀន ការរំលឹកអោយដឹងខ្លួន ការប្រដៅតម្រង់
និងបង្ហាត់ខាងឯសេចក្តីសុចរិត ដើម្បីអោយអ្នកសំណព្វរបស់ព្រះបានគ្រប់លក្ខណ៍
ហើយមានគ្រប់ទាំងចំណេះសំរាប់ធ្វើការល្អគ្រប់មុខ។

**៧.សេចក្តីសង្គ្រោះនិងជីវិតអស់កល្ប**
ត្រូវបានផ្តល់មកតាមរយៈការខ្ចាយឈាមរបស់ព្រះជាម្ចាស់នៅលើឈើឆ្កាងនិងការសុគតជួសបាបរបស់ទ្រង់ ។
សេចក្តីសង្គ្រោះគឺជាអំណោយដែលគ្មានល័ក្ខខ័ណ្ឌសម្រាប់អស់អ្នកណាដែលទទួលព្រះយេស៊ូវជាព្រះអម្ចាស់
ហើយជាព្រះសង្គ្រោះសម្រាប់ជីវិតគេ ហើយវាជាព្រះគុណ ។ សេចក្តីសង្គ្រោះគឺសាកសមនឹងមនុស្សដែលដាក់
សេចក្តីជំនឿរបស់គាត់លើការងាររបស់ព្រះយេស៊ូវ ។ ការប្រែចិត្តគឺជាការត្រឡប់ទៅរកព្រះវិញដោយជំនឿ បែរចេញពីអំពើបាបវាជា
ផ្នែកមួយតែមិនមែនទាំងស្រុងនោះទេ។ អស់អ្នកណាដែលទទួលយកព្រះយេស៊ូវគ្រីស្ទដោយជំនឿនោះគឺត្រូវបានកើតជាថ្មី
អំពើបាបរបស់គេត្រូវបានអត់ទោស បានក្លាយជាកូនព្រះ កើតជាថ្មីក្នុងព្រះគ្រីស្ទ
ហើយត្រូវបានប្រថាប់ត្រាដោយព្រះវិញ្ញាណបរិសុទ្ធសម្រាប់ថ្ងៃនៃការរំដោះ ដោយអំណាចចេស្តានៃព្រះ។

**៨.ពួកជំនុំជាសកល**
មាននៅក្នុងអស់អ្នកណាដែលបានកើតជាថ្មីហើយទទួលបុណ្យជ្រមុជដោយនូវព្រះវិញ្ញាណបរិសុទ្ធអោយចូលក្នុងរូបកាយនៃព្រះគ្រីស្ទ
នៅពេលកើតជាថ្មី ។ ព្រះអម្ចាស់យេស៊ូវគ្រីស្ទគឺជាសិរសា ជាអ្នកសង់
ជាម្ចាស់និងជាអ្នកផ្គត់ផ្គង់សម្រាប់ពួកជំនុំ។យើងជឿលើស្វ័យភាពរបស់ពួកជំនុំក្នុងតំបន់។

**៩.ពួកជំនុំក្នុងតំបន់**ត្រូវបានបង្កើតឡើងសម្រាប់ថ្វាយបង្គំ ការស្អាងពួកអ្នកជឿ ការប្រកប
ធ្វើទីបន្ទាល់ទៅដល់លោកិយនិងបង្កើតសិស្សសម្រាប់ព្រះគ្រីស្ទ ។
វាគឺជាអវៈយវៈដ៏សំខាន់ដែលព្រះបានប្រើដើម្បីសម្រេចនូវមហាបេសកកម្ម ហើយទទួលបាននូវសិទ្ធិ
និងអំណាចពីព្រះគ្រីស្ទក្នុងការបំពេញការងារនោះ។

**១០.អំណោយទានខាងវិញ្ញាណ**
ត្រូវបានផ្តល់ដល់សមាជិកនិមួយៗនៃរូបកាយរបស់ព្រះគ្រីស្ទសម្រាប់ការល្អដល់រូបកាយតាមព្រះហឫទ័យព្រះ ។ យើងក៏ជឿដែរថា
ព្រះគ្រីស្ទបានប្រទានអំណោយទានជាមនុស្សទៅដល់ពួកជំនុំដើម្បីបំពាក់បំប៉នមនុស្សសុចរិតរបស់ព្រះអោយបំពេញការងារ ។
យើងជឿថាអំណោយទានជាទីសម្គាល់គឺត្រូវបានផ្តល់អោយដើម្បីធ្វើការបញ្ជាក់អំពីព្រះបន្ទូលដែលមកតាមពួកសាវករបស់ព្រះ

ហើយដើម្បីបញ្ជាក់ថាវាគឺពិតជាព្រះបន្ទូលព្រះពិតមែន (២កូរិនថូស១២៖១២) តែទោះជាយ៉ាងណាក៏ដោយនៅពេលដែលពួកជំនុំត្រូវបានបង្កើតឡើង ហើយនៅពេលដែលសញ្ញាថ្មីត្រូវបានសរសេរចប់សព្វគ្រប់អំណោយទានខាងការធ្វើទីសម្គាល់ទាំងនោះក៏ត្រូវបានបញ្ចប់ទៅវិញដែរ(ហេព្រើ២៖៣-៤ រ៉ូម១០៖១៧)។

**១១. បញ្ញត្តិសម្រាប់ពួកជំនុំ** មានការជ្រមុជដោយទឹក និងពិធីលៀងព្រះអម្ចាស់។ ការជ្រមុជដោយទឹកដោយមុជចូលទៅក្នុងទឹកគឺជាការស្តាប់បង្គាប់តាមរយៈសេចក្តីសង្គ្រោះវា គឺជានិមិត្តសញ្ញានៃការស្លាប់ខាងឯអំពើបាបរបស់ពួកអ្នកជឿ ការកប់ជីវិតចាស់ ហើយរស់ឡើងវិញក្នុងជីវិតថ្មី។ ពិធីលៀងព្រះអម្ចាស់ត្រូវបានធ្វើឡើងដើម្បីប្រកប និងរួបរួមជាមួយព្រះគ្រីស្តជាសំគាល់នៃការរំលឹកអំពីការសុគតនិងការយាងមកជាលើកទី២របស់ទ្រង់ ។

**១២. យើងជឿថាគ្រប់អ្នកជឿទាំងអស់** គួរតែរស់នៅសម្រាប់ព្រះគ្រីស្ត មិនមែនសម្រាប់ខ្លួនឯងនោះទេហើយតាមរយៈការគង់នៅរបស់ព្រះវិញ្ញាណបរិសុទ្ធគេគួរតែអនុញ្ញាតអោយព្រះគ្រីស្តរស់នៅក្នុងជីវិតគេ ។ តាមរយៈការកើនឡើងក្នុងការស្តាប់បង្គាប់ព្រះបន្ទូលរបស់ព្រះអ្នកជឿម្នាក់ៗគួរតែពេញវ័យ និងលូតលាស់ទៅរកភាពដូចជាព្រះគ្រីស្តកាន់តែខ្លាំងឡើង ។ នៅក្រោមអំណាចនៃពួកជំនុំក្នុងតំបន់អ្នកជឿម្នាក់ៗគួរតែចូលរួមជាបុគ្គលក្នុងការបង្កើតសិស្សដើម្បីសម្រេចមហាបេសកកម្ម ធ្វើការល្អហើយបង្កើតផលផ្លែដើម្បីថ្វាយសិរីល្អដល់ព្រះ។

**១៣. សេចក្តីអធិស្ឋាន** គឺជាធនធានមួយដ៏អស្ចារ្យសម្រាប់គ្រប់ទាំងអ្នកជឿនិងពួកជំនុំក្នុងការទំនាក់ទំនងជាមួយនឹងព្រះដើម្បីបង្ហាញពីការសរសើរ ការអរគុណ ការលន់តួរ ការទូលអង្វរជំនួសសំរាប់ខ្លួនឯង និងអ្នកដ៏ទៃ។

**១៤. ការយាងត្រលប់មកវិញរបស់ព្រះគ្រីស្ត** គឺជិតមកដល់ហើយ ទ្រង់នឹងយាងមកវិញក្នុងរូបកាយជាមនុស្ស ហើយគ្រប់ទាំងអ្នកជឿនឹងបានឃើញក្នុងគ្រាឆក់យក ហើយគ្រប់ទាំងមនុស្សនឹងឃើញក្នុងការយាងមកជាលើកទីពីររបស់ទ្រង់ដើម្បីតាំងនគរនៃព្រះនៅផែនដី។ អ្នកបានសង្គ្រោះនឹងរស់ឡើងវិញក្នុងជីវិតអស់កល្បហើយបានព្រះពរនៅនគរឋានសួគ៌ ហើយអ្នកដែលមិនបានសង្គ្រោះក៏នឹងរស់ឡើងក្នុងជីវិតអស់កល្បហើយត្រូវទទួលទោសនៅក្នុងបឹងដែលឆេះជាភ្លើង។